# នីតិវិធីនៃការដាក់ទណ្ឌកម្ម
# ពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អ្នកផ្គត់ផ្គង់

## សេចក្តីផ្តើម

1. ក្នុងនាមជាស្ថាប័នផ្តល់ហិរញ្ញប្បទានដ៏ធំមួយដែលដើរតួសំខាន់ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់ មូលនិធិសកលទទួលស្គាល់នូវសារៈសំខាន់នៃគណនេយ្យភាពរបស់អ្នកផ្គត់ផ្គង់ ហើយនិងតម្លាភាព និងភាពអាចប្រមើលទុកបាននៃប្រតិបត្តិការរបស់ខ្លួន។

2. ដូចមានចែងក្នុងឯកសារក្របខ័ណ្ឌរបស់ខ្លួន គោលការណ៍ស្នូលរបស់មូលនិធិសកល គឺធ្វើប្រតិបត្តិការដោយមានការបើកទូលាយ តម្លាភាព និងភាពទទួលខុសត្រូវ។ ដើម្បីស្របតាមគោលការណ៍ស្នូលនេះ មូលនិធិសកលនឹងចាត់វិធានការដើម្បីធានាឲ្យប្រាកដថាសកម្មភាពដែលផ្តល់ហិរញ្ញប្បទានរបស់ខ្លួន ដែលរួមមានការធ្វើលទ្ធកម្មសាជីវកម្ម ការផ្តល់ប្រាក់ជំនួយ និងបុគ្គលិករបស់ខ្លួនប្រកាន់ភ្ជាប់នូវនិយាមសីលធម៌ជាអតិប្បរមា។

3. គោលបំណងនៃក្រមសីលធម៌សម្រាប់អ្នកផ្គត់ផ្គង់របស់មូលនិធិសកល ("ក្រមសីលធម៌") គឺដើម្បីឲ្យអ្នកផ្គត់ផ្គង់មានការប្តេជ្ញាចិត្តក្នុងការរក្សាសុចរិតភាពនៃប្រតិបត្តិការ និងសកម្មភាពលទ្ធកម្មដែលផ្តល់ជំនួយដោយមូលនិធិសកល ដោយអនុលោមតាមគោលការណ៍ស្នូលរបស់មូលនិធិសកល។

4. មូលនិធិសកលរំពឹងថាអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ភ្នាក់ងារ ឈ្មួញកណ្តាល ទីប្រឹក្សា និងអ្នកម៉ៅការ ("អ្នកផ្គត់ផ្គង់") ក្នុងនោះរួមមានអ្នកពាក់ព័ន្ធ និយោជិត អ្នកម៉ៅការបន្ត ភ្នាក់ងារ និងឈ្មួញកណ្តាលនៃអ្នកផ្គត់ផ្គង់ទាំងអស់ (ដែលអ្នកចូលរួមនីមួយៗគឺជា "តំណាងអ្នកផ្គត់ផ្គង់") នឹងគោរពតាមនិយាមសីលធម៌ជាអតិប្បរមា ក្នុងសកម្មភាពដែលផ្តល់ជំនួយដោយមូលនិធិសកល រួមមានការផ្គត់ផ្គង់ផលិតផល និង/ឬសេវាកម្មដល់មូលនិធិសកល ឬស្ថាប័នទទួលហិរញ្ញប្បទានពីមូលនិធិសកល ដែលរួមមានការិយាល័យទទួលជំនួយផ្ទាល់ ស្ថាប័នទទួលជំនួយបន្ត ស្ថាប័នទទួលជំនួយផ្សេងៗ យន្តការសម្របសម្រួលប្រចាំប្រទេស ភ្នាក់ងារលទ្ធកម្ម និងអតិថិជន។ ការរំពឹងទុករបស់មូលនិធិសកលស្តីពីការប្រព្រឹត្តរបស់អ្នកផ្គត់ផ្គង់បានចែងក្នុងក្រមសីលធម៌នេះ។

5. មូលនិធិសកលអាចនឹងដកសិទ្ធិចូលរួមក្នុងការប្រកួតប្រជែង លើការផ្គត់ផ្គង់ដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិសកល សម្រាប់រយៈពេលមួយមានកំណត់ ឬគ្មានកំណត់ទៅលើអ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ ក្នុងករណីមូលនិធិសកលរកឃើញថាអ្នកផ្គត់ផ្គង់ ឬ

តំណាងអ្នកផ្គត់ផ្គង់បានរំលោភលើក្រមសីលធម៌ដោយផ្ទាល់ ឬដោយប្រយោល(តាមរយៈភ្នាក់ងារ ឬឈ្មួញកណ្ដាល) រួមមានការប្រព្រឹត្តអំពើពុករលួយ គៃបន្លំ ឃុបឃិត ការប្រកួតប្រជែងមិនស្មើភាព ឬការបង្ខិតបង្ខំក្នុងការប្រកួតប្រជែងដើម្បីទទួលយក ឬអនុវត្តកិច្ចសន្យាដែលផ្ដល់ហិរញ្ញប្បទានដោយមូលនិធិសកល។

6. គោលបំណងនៃការដាក់ទណ្ឌកម្មនេះគឺដើម្បីការពារផលប្រយោជន៍ ធនធាន និង កេរ្តិ៍ឈ្មោះរបស់មូលនិធិសកល រួមទាំងស្ថាប័នដែលទទួលជំនួយពីមូលនិធិសកល និងដើម្បីធានារក្សានូវការជឿជាក់ និងទំនុកចិត្តពីសាធារណៈជនក្នុងការសម្រេចចិត្ត និងសកម្មភាពផ្ដល់ជំនួយរបស់មូលនិធិសកល។

7. គោលបំណងនៃឯកសារនេះ គឺដើម្បីបង្ហាញអំពីនីតិវិធីរបស់មូលនិធិសកលក្នុងការដាក់ទណ្ឌកម្មចំពោះអ្នកផ្គត់ផ្គង់ ("នីតិវិធីនៃការដាក់ទណ្ឌកម្ម")។

## គណៈកម្មការវិន័យ

### សមាសភាព

8. គណៈកម្មការដែលរួមមានសមាជិកជាន់ខ្ពស់នៃលេខាធិការដ្ឋានមូលនិធិសកល និងភាគីឯករាជ្យពីស្ថាប័នខាងក្រៅ ("គណៈកម្មការវិន័យ") ត្រូវទទួលខុសត្រូវក្នុងការអនុវត្តន៍នីតិវិធីនៃការដាក់ទណ្ឌកម្មនេះ។

9. គណៈកម្មការវិន័យត្រូវមានសមាជិកអចន្ត្រៃយ៍បីរូប និងសមាជិកបំពេញបីរូប ៖
   (a) សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការវិន័យមាន នាយកសេវាកម្មសាជីវកម្ម នាយកកម្មវិធីប្រចាំប្រទេស និងនាយកហិរញ្ញវត្ថុប្រចាំប្រទេស។
   (b) នាយកប្រតិបត្តិត្រូវអញ្ជើញបុគ្គលបីរូបពីស្ថាប័នខាងក្រៅ ដើម្បីធ្វើជាសមាជិកបំពេញនៃគណៈកម្មការវិន័យ ដោយធ្វើការពិចារណាលើលក្ខណៈសម្បត្តិដូចជា (i) ភាពគួរឲ្យទុកចិត្តបាន និងឯករាជ្យភាព (ii) ជំនាញ និងបទពិសោធន៍ពាក់ព័ន្ធ (iii) ការយល់ដឹងអំពីមូលនិធិសកល និងសកម្មភាពនានារបស់មូលនិធិសកល (iv) ការប្ដេជ្ញាចិត្ត និងលទ្ធភាពដែលអាចចូលរួមក្នុងកិច្ចប្រជុំនានា និង (v) តុល្យភាពយេនឌ័រ។
   (c) នាយកប្រតិបត្តិត្រូវអញ្ជើញបុគ្គលមួយរូបក្នុងចំណោមបុគ្គលបីរូបមកពីស្ថាប័នខាងក្រៅ ដែលមានលក្ខណៈសម្បត្តិដូចមានចែងខាងលើឲ្យធ្វើជាប្រធាននៃគណៈកម្មការវិន័យ។
   (d) ការតែងតាំងមុខតំណែងរបស់សមាជិកខាងក្រៅ ត្រូវធ្វើឡើងសម្រាប់រយៈពេលពីរឆ្នាំ និងអាចត្រូវបានបន្តដោយនាយកប្រតិបត្តិសម្រាប់រយៈពេលពីរឆ្នាំបន្ថែមទៀត។

10. អគ្គាធិការអ្នកផ្តល់ប្រឹក្សាផ្នែកច្បាប់ និងអ្នកតំណាងជាន់ខ្ពស់មួយរូបពីអង្គភាពលទ្ធកម្មសាជីវកម្ម ឬអង្គភាពគ្រប់គ្រងឱសថ (ទៅតាមការគួរ) ត្រូវផ្តល់ប្រឹក្សាដល់គណៈកម្មការវិន័យ និងត្រូវចូលរួមក្នុងកិច្ចប្រជុំទាំងអស់របស់គណៈកម្មការវិន័យក្នុងតួនាទីជាទីប្រឹក្សា។ សមាជិកមួយរូបនៃអង្គភាពសេវាកម្មច្បាប់ត្រូវធ្វើជាលេខាធិការនៃគណៈកម្មការវិន័យ។

11. ប្រធានគណៈកម្មការវិន័យអាចស្នើសុំបេក្ខភាពពីសមាជិកដ៏ទៃនៃលេខាធិការដ្ឋាន ឬអ្នកជំនាញមកពីស្ថាប័នខាងក្រៅមកធ្វើជាប្រធាន ក្នុងករណីចាំបាច់ និងតាមការគួរ ដើម្បីជួយដល់ការពិភាក្សា និងការសម្រេចនានារបស់គណៈកម្មការវិន័យ។

12. សមាជិក ទីប្រឹក្សា និងអ្នកជំនាញនៃគណៈកម្មការវិន័យ ត្រូវគោរពតាមគោលការណ៍ស្តីពីក្រមសីលធម៌ និងទំនាស់ផលប្រយោជន៍របស់មូលនិធិសកល (Policy on Ethics and Conflicts of Interest for Global Fund Institutions)។ មុនពេលចាប់ផ្តើមកិច្ចប្រជុំគណៈកម្មការវិន័យ អ្នកចូលរួមក្នុងកិច្ចប្រជុំទាំងអស់ត្រូវប្រកាសថាតើពួកគេមានការជាប់ពាក់ព័ន្ធក្នុងកិច្ចការ ដែលនឹងត្រូវធ្វើការពិចារណា ឬមានទំនាក់ទំនងជាមួយនឹងអ្នកផ្គត់ផ្គង់ ឬអ្នកតំណាងអ្នកផ្គត់ផ្គង់ ដែលការប្រព្រឹត្តរបស់ពួកគេកំពុងត្រូវបានពិនិត្យឡើងវិញ ឬមានការជាប់ពាក់ព័ន្ធផ្សេងៗដែលអាចធ្វើអោយមានទំនាស់ប្រយោជន៍ ឬភាពលំអៀង។

## ដំណើរការ

13. គណៈកម្មការវិន័យត្រូវធ្វើការពិភាក្សា និងពិចារណាក្នុងកិច្ចប្រជុំផ្ទាល់ ឬជួបប្រជុំតាមរយៈទូរស័ព្ទ (Conference Call) ក្នុងករណីមិនអាចជួបប្រជុំផ្ទាល់។

14. សម្រាប់កិច្ចប្រជុំគណៈកម្មការវិន័យ ត្រូវមានកូរ៉ុមសមាជិកអចិន្ត្រៃយ៍ពីរូប និងសមាជិកបំពេញពីររូប (រួមទាំងប្រធាន)។ គណៈកម្មការវិន័យត្រូវព្យាយាមដើម្បីទទួលបានសេចក្តីសម្រេចដោយមានការយល់ស្របជាឯកច្ឆន្ទ។ ក្នុងករណីគ្មានការយល់ស្របជាឯកច្ឆន្ទ សេចក្តីសម្រេចនឹងត្រូវធ្វើឡើងដោយមតិភាគច្រើន។ សមាជិកនីមួយៗនៃគណៈកម្មការវិន័យត្រូវមានមួយសម្លេង។ ក្នុងករណីមានសម្លេងឆ្នោតស្មើគ្នា សម្លេងឆ្នោតរបស់ប្រធានគឺជាសម្លេងឧត្តមានុភាព។

15. គណៈកម្មការវិន័យត្រូវធ្វើកំណត់ហេតុកិច្ចប្រជុំ និងសេចក្តីសម្រេចរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងត្រូវរក្សាព័ត៌មានទាំងអស់ជាការសម្ងាត់។ ព័ត៌មានដែលផ្តល់ដោយ OIG នឹងត្រូវរក្សាទុកដោយ OIG

ទៅតាមគោលការណ៍របស់ OIG។ លេខាធិការរបស់គណៈកម្មការវិន័យ នឹងរៀបចំទុកដាក់ឯកសារដែលបានអនុម័តដោយគណៈកម្មការវិន័យ និងត្រូវចងចាំអំពីការពិភាក្សា និងពិចារណាការសម្រេច និងអនុសាសន៍របស់គណៈកម្មការវិន័យ។

16. គណៈកម្មការពិន័យត្រូវផ្តល់អនុសាសន៍របស់ខ្លួនដល់នាយកប្រតិបត្តិ ដើម្បីធ្វើការសម្រេចចុងក្រោយ។

## នីតិវិធីនៃការដាក់ទណ្ឌកម្ម

### ការបញ្ជូនករណីទៅគណៈកម្មការវិន័យ

17. ផ្អែកលើការសម្រេចរបស់នាយកប្រតិបត្តិ គណៈកម្មការវិន័យត្រូវជួបប្រជុំពិចារណាផ្តល់អនុសាសន៍ឲ្យមូលនិធិសកលដើម្បីដាក់ទណ្ឌកម្មចំពោះអ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ ក្នុងកាលៈទេសៈណាមួយដូចខាងក្រោម ៖
   (a) បន្ទាប់ពីមានការសម្រេចដោយអគ្គាធិការថាមានភស្តុតាងច្បាស់លាស់ និងអាចទុកចិត្តបានដែលធ្វើឲ្យការសង្ស័យសមហេតុផលថាមានករណីរំលោភលើក្រមសីលធម៌ ក្នុងនោះរួមមានការប្រព្រឹត្តអំពើពុករលួយ គៃបន្លំ ឃុបឃិត ការប្រកួតប្រជែងមិនស្មើភាព ឬការបង្ខិតបង្ខំក្នុងការប្រកួតប្រជែងដើម្បីទទួលយក ឬអនុវត្តកិច្ចសន្យាដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិសកល។
   (b) សេចក្តីជូនដំណឹងពីការដាក់ទណ្ឌកម្មត្រូវបានបញ្ជូនទៅអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ដោយអង្គការដៃគូ ឬដោយស្ថាប័នទទួលជំនួយពីមូលនិធិសកល ចំពោះការប្រព្រឹត្តទាំងឡាយណាដែលជាការរំលោភលើក្រមសីលធម៌ ឬការប្រព្រឹត្តទាំងឡាយណាដែលខុសច្បាប់ ឬខុសក្រមសីលធម៌។
   (c) សេចក្តីជូនដំណឹងពីលទ្ធផលនៃការស៊ើបអង្កេត ចំណាត់ការផ្លូវច្បាប់ ឬរបកគំហើញណាមួយទាំងរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាល ឬការដាក់ពិន័យដោយអាជ្ញាធរជាតិ ឬអន្តរជាតិ ចំពោះការប្រព្រឹត្តដែលជាការរំលោភលើក្រមសីលធម៌នេះ។
   (d) ការរំលោភជាក់ស្តែងលើកិច្ចសន្យារវាងមូលនិធិសកល និងអ្នកផ្គត់ផ្គង់ ឬរវាងស្ថាប័នទទួលជំនួយ និងអ្នកផ្គត់ផ្គង់ ឬ
   (e) មានព័ត៌មានច្បាស់លាស់ និងអាចទុកចិត្តបានពីប្រភពណាមួយដែលបង្ហាញថាថវិកា ទ្រព្យសម្បត្តិ ឬធនធានរបស់មូលនិធិសកលប្រឈមនឹងហានិភ័យដែលកើតឡើងពីការប្រព្រឹត្តរបស់អ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់។

## របាយការណ៍បឋម

18. បន្ទាប់ពីបញ្ជូនទៅគណៈកម្មការវិន័យសម្រាប់ករណីដែលមានចែងក្នុងប្រការ 17(a) ដល់ (e) ខាងលើ, ការិយាល័យអគ្គាធិការ ដោយមានការប្រឹក្សាជាមួយលេខាធិការដ្ឋាន ត្រូវធ្វើរបាយការណ៍ជាលាយល័ក្ខអក្សរ មកគណៈកម្មការវិន័យដោយរាយការណ៍លម្អិតអំពី ៖
    - (a) ការប្រព្រឹត្តដែលអាចត្រូវបានដាក់ទណ្ឌកម្ម
    - (b) ព័ត៌មាន និងភស្តុតាងពាក់ព័ន្ធ រួមមានរបកគំហើញ និងការសន្និដ្ឋានចេញពីការស៊ើបអង្កេតដែលទាក់ទងនឹងអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់
    - (c) ការខូចខាត ឬការខាតបង់ជាក់ស្តែង ដែលអាចកើតមានឡើង ចំពោះមូលនិធិសកល ឬស្ថាប័នទទួលជំនួយពីមូលនិធិសកល (មិនថាការខាតបង់ផ្នែកហិរញ្ញវត្ថុ ឬការខាតបង់ផ្នែកផ្សេងៗទៀតឡើយ)
    - (d) កត្តាដែលធ្វើឲ្យស្ថានភាពមានភាពធ្ងន់ធ្ងរ ឬធូរស្រាល រួមមានថាតើអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់បានសហការក្នុងការធ្វើសវនកម្ម ឬការស៊ើបអង្កេតដែរឬទេ ឬសហការក្នុងកិច្ចការផ្សេងទៀតដែលកំពុងពិនិត្យឡើងវិញដោយអគ្គាធិការ និងកម្រិតនៃភាពជោគជ័យ និងសារៈប្រយោជន៍នៃការសហការនោះចំពោះអគ្គាធិការ
    - (e) ព័ត៌មានពាក់ព័ន្ធទាំងឡាយណាដែលអាចច្រានចោលការចោទប្រកាន់ចំពោះអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ ឬដែលអាចបន្ធូរបន្ថយការចោទប្រកាន់ចំពោះអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ និង
    - (f) ព័ត៌មានផ្សេងទៀតដែលអាចពាក់ព័ន្ធនឹងការពិភាក្សានិងពិចារណារបស់គណៈកម្មការវិន័យ

## ការជូនដំណឹងដល់អ្នកផ្គត់ផ្គង់

19. កម្មវត្ថុចំពោះការលើកលែងដល់ការទំនាក់ទំនងជាមួយនឹងអ្នកផ្គត់ផ្គង់ ដូចរៀបរាប់ខាងក្រោម គណៈកម្មការវិន័យត្រូវធ្វើរសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរ ដល់អ្នកផ្គត់ផ្គង់មុននឹងផ្តល់អនុសាសន៍ឲ្យដាក់ទណ្ឌកម្ម និងទុកពេលសមស្របសម្រាប់អ្នកផ្គត់ផ្គង់ដើម្បីឆ្លើយតបនឹងការចោទប្រកាន់។

20. សេចក្តីជូនដំណឹងត្រូវបញ្ជាក់ ថាការប្រព្រឹត្តដែលអាចត្រូវបានដាក់ទណ្ឌកម្មរបស់អ្នកផ្គត់ផ្គង់ត្រូវបានបញ្ជូនទៅគណៈកម្មការវិន័យដើម្បីធ្វើការពិចារណា និងត្រូវផ្តល់ការពិពណ៌នាសង្ខេបអំពីការប្រព្រឹត្តនោះ និងត្រូវសំណូមពរការបំភ្លឺ និងការឆ្លើយតបពីអ្នកផ្គត់ផ្គង់ និងដាក់ពេលកំណត់

សមស្របដើម្បីទទួលចម្លើយពីអ្នកផ្គត់ផ្គង់។ គណៈកម្មការវិន័យ មិនត្រូវបានតម្រូវឲ្យបញ្ជាក់អំពីភស្តុតាង និងសាក្សីសម្រាប់ការចោទប្រកាន់ចំពោះការប្រព្រឹត្តដែលអាចត្រូវបានដាក់ទណ្ឌកម្ម ឬផ្តល់ឯកសារថតចម្លងពាក់ព័ន្ធ ដែលបានប្រគល់ជូនគណៈកម្មការវិន័យ។

21. គណៈកម្មការវិន័យមិនត្រូវបានតម្រូវឲ្យធ្វើការទាក់ទងជាមួយនឹងអ្នកផ្គត់ផ្គង់ មុននឹងការផ្តល់អនុសាសន៍ឲ្យមានការដាក់ទណ្ឌកម្មក្នុងកាលៈទេសៈដូចខាងក្រោម ៖
   (a) ប្រសិនបើករណីដែលដាក់ជូនគណៈកម្មការវិន័យមានជាប់ទាក់ទងទៅនឹង ការស៊ើបអង្កេត ឬការធ្វើសវនកម្មដោយ OIG, អគ្គាធិការអាចដាក់កំហិតដោយមានការសម្រេចចិត្តផ្ទាល់ លើការទំនាក់ទំនងទាំងឡាយជាមួយនឹងអ្នកផ្គត់ផ្គង់ទាក់ទងនឹង ការស៊ើបអង្កេត ឬការធ្វើសវនកម្ម ក្នុងនោះរួមមានថាតើត្រូវជូនដំណឹងដល់អ្នកផ្គត់ផ្គង់ អំពីការពិតនៃការស៊ើបអង្កេតដែរឬទេ
   (b) ក្នុងករណីអ្នកផ្តល់ប្រឹក្សាផ្នែកច្បាប់ណែនាំមិនឲ្យមានការទំនាក់ទំនងក្នុងមូលហេតុផ្នែកច្បាប់
   (c) ក្នុងករណីអាជ្ញាធរជាតិបានសំណូមពរឲ្យមូលនិធិសកលដាក់កំហិតលើការផ្សព្វផ្សាយព័ត៌មាន
   (d) ក្នុងករណីការទំនាក់ទំនងជាមួយនឹងអ្នកផ្គត់ផ្គង់ អាចនឹងធ្វើឲ្យអ្នកផ្តល់ព័ត៌មាន និងសាក្សីប្រឈមនឹងគ្រោះថ្នាក់ ឬ
   (e) ក្នុងកាលៈទេសៈបន្ទាន់ដែលគណៈកម្មការវិន័យចាត់ទុកថាផលប្រយោជន៍ ធនធាន ឬកេរ្តិ៍ឈ្មោះរបស់មូលនិធិសកល ឬស្ថាប័នទទួលជំនួយ និងការិយាល័យទទួលជំនួយផ្ទាល់ គឺកំពុងប្រឈមនឹងហានិភ័យ

22. ករណីអាចបញ្ជូនទៅនាយកប្រតិបត្តិដើម្បីធ្វើការសម្រេច ថាតើត្រូវកោះប្រជុំគណៈកម្មការវិន័យ ទាំងក្នុងពេលស៊ើបអង្កេត ឬធ្វើសវនកម្មដោយ OIG ឬបន្ទាប់ពីការផ្សើររបាយការណ៍ចុងក្រោយដោយ OIG។ ការផ្សព្វផ្សាយរបាយការណ៍ OIG ចុងក្រោយ ត្រូវបានធ្វើឡើងតាមគោលការណ៍ផ្សព្វផ្សាយព័ត៌មានសម្រាប់របាយការណ៍ OIG (Disclosure Policy for OIG Reports)។ ប្រសិនបើករណីដែលដាក់ជូនគណៈកម្មការវិន័យមានជាប់ទាក់ទងទៅនឹងការស៊ើបអង្កេត ឬការធ្វើសវនកម្មដែលកំពុងដំណើរការដោយ OIG ឬការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ OIG ចុងក្រោយត្រូវបានដាក់កំហិតដោយយោងទៅតាមគោលការណ៍ផ្សព្វផ្សាយព័ត៌មាន, អគ្គាធិការត្រូវរក្សាការសម្រេចចុងក្រោយចំពោះការទំនាក់ទំនងជាមួយនឹងអ្នកផ្គត់ផ្គង់។ របាយការណ៍ចេញដោយ OIG អំពីការស៊ើបអង្កេត និងការធ្វើសវនកម្ម និងភស្តុតាងទាំងឡាយក្នុងការស៊ើបអង្កេត និងមានក្នុងរបាយការណ៍ មិនត្រូវផ្តល់ឲ្យអ្នកផ្គត់ផ្គង់ទេ លុះត្រាតែមានការយល់ព្រមពីអគ្គាធិការ។

**ការឆ្លើយតបរបស់អ្នកផ្គត់ផ្គង់**

23. អ្នកផ្គត់ផ្គង់គួរឆ្លើយតបទៅគណៈកម្មាការវិន័យចំពោះការចោទប្រកាន់ ក្នុងអំឡុងពេលកំណត់ដែលមានបញ្ជាក់ក្នុងសេចក្តីជូនដំណឹងដល់អ្នកផ្គត់ផ្គង់។

24. គណៈកម្មការវិន័យអាចចាត់ទុកលិខិតជាលាយល័ក្ខអក្សររបស់អ្នកផ្គត់ផ្គង់ ជាការឆ្លើយតបចំពោះការចោទប្រកាន់ដែលជាប់ពាក់ព័ន្ធនឹងការសម្រេចដាក់ទណ្ឌកម្ម ។ ក្នុងកាលៈទេសៈពិសេស និងដោយការសម្រេចពីគណៈកម្មការវិន័យ គណៈកម្មការវិន័យអាចអនុញ្ញាតឲ្យមានការជួបប្រជុំដោយផ្ទាល់ ឬការទំនាក់ទំនងដោយផ្ទាល់ផ្សេងទៀតរវាងអ្នកផ្គត់ផ្គង់ និងគណៈកម្មការវិន័យ។ គណៈកម្មការវិន័យមិនត្រូវបានតម្រូវឱ្យអនុញ្ញាតឲ្យមានការជួបប្រជុំដោយផ្ទាល់ ឬការទំនាក់ទំនងដោយផ្ទាល់មុននឹងធ្វើការសម្រេចចិត្ត ឬផ្តល់អនុសាសន៍នោះទេ។

## ការផ្តល់អនុសាសន៍អំពីការដាក់ទណ្ឌកម្ម

25. គណៈកម្មការវិន័យ ត្រូវជួបប្រជុំដើម្បីពិនិត្យឡើងវិញនូវភស្តុតាងចោទប្រកាន់ចំពោះអ្នកផ្គត់ផ្គង់ ក្នុងនោះរួមមានរបាយការណ៍របស់ OIG, ការឆ្លើយតបរបស់អ្នកផ្គត់ផ្គង់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។ គណៈកម្មការវិន័យត្រូវធ្វើការពិចារណាអំពីការណែនាំ ឬមតិយោបល់របស់អង្គភាពពាក់ព័ន្ធនៃលេខាធិការដ្ឋាន ដែលអាចនឹងត្រូវបានប៉ះពាល់ដោយវិធានការរបស់គណៈកម្មការវិន័យ មុននឹងសម្រេចចាត់វិធានការសមស្របណាមួយ។

26. គណៈកម្មការវិន័យត្រូវធ្វើការសម្រេចលើការផ្តល់ ឬមិនផ្តល់អនុសាសន៍ឲ្យមានការដាក់ទណ្ឌកម្មលើអ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ និងលក្ខណៈ ទំហំ និងរយៈពេលនៃការដាក់ទណ្ឌកម្មនោះ។

27. គណៈកម្មការវិន័យ ត្រូវផ្តល់អនុសាសន៍ឲ្យមានការដាក់ទណ្ឌកម្មក្នុងករណីគណៈកម្មការវិន័យយល់ថាការដាក់ទណ្ឌកម្មមានភាពចាំបាច់ ឬសមស្របដើម្បីការពារផលប្រយោជន៍ ធនធាន និងកេរ្តិ៍ឈ្មោះរបស់មូលនិធិសកល ក្នុងនោះរួមមានស្ថាប័នទទួលជំនួយពីមូលនិធិសកល។

28. បញ្ជីរៀបរាប់កត្តានានាដែលអាចនឹងប៉ះពាល់ដល់ការសម្រេចចិត្ត និងការផ្តល់អនុសាសន៍របស់គណៈកម្មការវិន័យរួមមាន ៖
    (a) ភាពធ្ងន់ធ្ងរនៃការប្រព្រឹត្ត
    (b) កម្រិតនៃការជាប់ទាក់ទងរបស់អ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ក្នុងសកម្មភាពដែលអាចត្រូវបានដាក់ទណ្ឌកម្ម
    (c) គុណភាពនៃភស្តុតាងដែលបានបង្ហាញ
    (d) ការខូចខាត ឬការខាតបង់ជាក់ស្តែង មិនថាការខាតបង់ផ្នែកហិរញ្ញវត្ថុ ឬការខាតបង់ផ្នែកផ្សេងៗទៀតឡើយ ដល់មូលនិធិសកលដែលបណ្តាលមកពីការប្រព្រឹត្តនោះ

(e) ការប្រព្រឹត្តពីអតីតកាលរបស់អ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ ដែលជាប់ទាក់ទងនឹងសកម្មភាពដែលអាចត្រូវបានដាក់ទណ្ឌកម្ម (ទោះមាន ឬមិនមានក្នុងកិច្ចសន្យាដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិសកលក៏ដោយ)

(f) កត្តាដែលធ្វើឲ្យស្ថានភាពមានភាពធ្ងន់ធ្ងរ រួមមានការប៉ុនប៉ងបិទបាំងការប្រព្រឹត្តខុស ឬការប្រព្រឹត្តដែលអាចត្រូវបានដាក់ទណ្ឌកម្ម ឬគំរាមគំហែង ឬធ្វើការសងសឹកចំពោះសាក្សី និងទង្វើរទាំងឡាយដែលប្រឆាំងនឹងច្បាប់របស់ប្រទេស(but not limited to)

(g) កត្តាដែលធ្វើឲ្យស្ថានភាពមានភាពធូរស្រាល រួមមានការជូនដំណឹងរបស់អ្នកផ្គត់ផ្គង់ដល់មូលនិធិសកល, ការសហការល្អរបស់អ្នកផ្គត់ផ្គង់ក្នុងកំឡុងពេលស៊ើបអង្កេតរបស់ OIG ដែលការសហការនោះផ្តល់សារៈប្រយោជន៍ចំពោះមូលនិធិសកល ឬក៏ជាសកម្មភាពរបស់អ្នកផ្គត់ផ្គង់ រួមមានការសហការដែលបានជួយសន្សំធនធាន ទ្រព្យសម្បត្តិ ឬមូលនិធិ ឬក៏ការធ្វើបដិទានណាមួយដល់មូលនិធិសកល

(h) ផលប៉ះពាល់នៃការប្រព្រឹត្តនោះមកលើប្រតិបត្តិការរបស់មូលនិធិសកល, អ្នកជំងឺ, ប្រជាជនគោលដៅ និងបទអន្តរាគមន៍, ទីផ្សារ, ការិយាល័យទទួលជំនួយផ្ទាល់, ការអនុវត្តន៍គម្រោងជំនួយ និងការផ្តល់សេវាកម្មចាំបាច់ផ្សេងៗទៀត

(i) ដូចការពិន័យដែលបានអនុវត្តពីមុនមកចំពោះកាលៈទេសៈស្រដៀងគ្នា

(j) រយៈពេលនៃការបញ្ឈប់សេវាកម្មជាបណ្តោះអាសន្ន ដែលអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់បានបំពេញ សម្រាប់ការប្រព្រឹត្តដែលជាកម្មវត្ថុនៃដំណើរការនៃការដាក់ទណ្ឌកម្ម

(k) កត្តាផ្សេងៗដែលគណៈកម្មការវិន័យយល់ថាមានភាពពាក់ព័ន្ធ

## លក្ខណៈ ទំហំ និងរយៈពេលនៃការដាក់ទណ្ឌកម្ម

29. គណៈកម្មការវិន័យអាចផ្តល់អនុសាសន៍ឲ្យដាក់ទណ្ឌកម្មមួយ ឬច្រើនដូចខាងក្រោមចំពោះអ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ ៖

(a) ***ការប្រឆាំងជំទាស់*** ៖ គណៈកម្មាការវិន័យអាចផ្តល់អនុសាសន៍ ឲ្យចេញសេចក្តីជំទាស់ជាសំបុត្ររិះគន់ជាផ្លូវការចំពោះការប្រព្រឹត្តរបស់អ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់

(b) ***លក្ខខ័ណ្ឌក្នុងការចូលរួមបន្ត***៖ ប្រសិនបើអាច ដោយពិចារណាលើកត្តាដូចមានចែងក្នុងកថាខ័ណ្ឌ 25 ខាងលើ គណៈកម្មការវិន័យអាចផ្តល់អនុសាសន៍ថាវិធានការមួយចំនួនដែលអនុវត្តដោយអ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ ក្នុងកាលបរិច្ឆេទជាក់លាក់ណាមួយ ជាលក្ខខ័ណ្ឌក្នុងការបន្តមានសិទ្ធិសម្រាប់កិច្ចសន្យា ឬសកម្មភាពដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិសកល

(c) ***ការបញ្ឈប់សកម្មភាព៖*** គណៈកម្មការវិន័យអាចផ្តល់អនុសាសន៍ ឲ្យប្រកាសថាអ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ មិនមានសិទ្ធិក្លាយជា ឬបន្តធ្វើជាអ្នកផ្គត់ផ្គង់របស់មូលនិធិសកល ការិយាល័យទទួលជំនួយផ្ទាល់ណាមួយ ស្ថាប័នផ្សេងៗដែលទទួលជំនួយពីមូលនិធិសកល ឬចូលរួមក្នុងកិច្ចសន្យាទាំងឡាយណាដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិសកល

I. ការបញ្ឈប់សកម្មភាពនេះ អាចសម្រាប់រយៈពេលមួយមានកំណត់ ឬគ្មានកំណត់

II. បន្ថែមពីលើនេះ រយៈពេលនៃការបញ្ឈប់សកម្មភាពអាចនឹងត្រូវបានកាត់បន្ថយក្នុងករណីអ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ គោរពតាមលក្ខខ័ណ្ឌនានាកំណត់ដោយគណៈកម្មការវិន័យ ក្នុងនោះរួមមានការអនុវត្តន៍តាមកម្មវិធីក្រមសីលធម៌សាជីវកម្ម និងក្បួនច្បាប់ម្ចាស់ជំនួយ, ការបណ្តុះបណ្តាលអំពីក្រមសីលធម៌ និងប្រឆាំងនឹងអំពើពុករលួយ, អ្នកតាមដានឯករាជ្យ, លក្ខខ័ណ្ឌដោះស្រាយបញ្ហាទាំងឡាយណាដែលកំណត់ដោយគណៈកម្មការវិន័យ និងបង្ហាញពីការសហការជាមួយនឹង OIG និងការស៊ើបអង្កេត និងសកម្មភាពពាក់ព័ន្ធរបស់ OIG។ គណៈកម្មការពិន័យ ក៏អាចកំណត់ថាដើម្បីបន្តទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងមូលនិធិសកល, រក្សាសិទ្ធិក្នុងការទទួលជំនួយ ឬចូលរួមក្នុងគម្រោង ឬសកម្មភាពដែលផ្តល់មូលនិធិដោយមូលនិធិសកល អ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ ត្រូវទទួលយកនូវវិធានការដោះស្រាយបញ្ហាទាំងនេះ។

(d) ***ផ្សេងៗ៖*** ការដាក់ទណ្ឌកម្មផ្សេងៗ ដែលគណៈកម្មការវិន័យយល់ថាសមស្របដែលរួមមានការបញ្ឈប់ជាបន្ទាន់នូវការចូលរួមរបស់អ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ក្នុងគម្រោងទាំងឡាយណាដែលកំពុងដំណើរការ។

30. ក្នុងករណីដែលគណៈកម្មការវិន័យផ្តល់អនុសាសន៍ឲ្យដាក់ទណ្ឌកម្ម ប៉ុន្តែលទ្ធផលនៃការស៊ើបអង្កេត (ដោយ OIG ឬអាជ្ញាធរជាតិ) មិនទាន់ចេញ គណៈកម្មការវិន័យអាចផ្តល់អនុសាសន៍ថាទណ្ឌកម្មនោះ ជាការដាក់ទណ្ឌកម្មបណ្តោះអាសន្ន និងត្រូវមានការពិនិត្យឡើងវិញនៅពេលការស៊ើបអង្កេតត្រូវបានបញ្ចប់។

## ការសម្រេចលើការដាក់ទណ្ឌកម្ម

31. មុននឹងជូនដំណឹងអំពីការសម្រេចចិត្ត និងអនុសាសន៍របស់ខ្លួនដល់នាយកប្រតិបត្តិ គណៈកម្មការវិន័យអាចជូនដំណឹងដល់អ្នកផ្គត់ផ្គង់ និងបង្ហាញអំពីអនុសាសន៍របស់ខ្លួន ក្នុងករណីគណៈកម្មការវិន័យយល់ថាមានភាពសមស្រប ។ គណៈកម្មការវិន័យនឹងទុករយៈពេល 14ថ្ងៃសម្រាប់អ្នកផ្គត់ផ្គង់ដើម្បីឆ្លើយតបនឹងការជូនដំណឹងនោះ។

32. គណៈកម្មការវិន័យត្រូវជូនដំណឹងអំពីអនុសាសន៍របស់ខ្លួន ដល់នាយកប្រតិបត្តិដែលជាអ្នកធ្វើការសម្រេចចុងក្រោយ។ នាយកប្រតិបត្តិអាចបញ្ជូនករណីនោះត្រឡប់ទៅគណៈកម្មការវិន័យ ដើម្បីធ្វើការពិភាក្សា និងពិចារណាបន្ថែម ក្នុងករណីមានការលេចឡើងនូវព័ត៌មានថ្មីទាក់ទងនឹងករណីនោះដែលអាចប៉ះពាល់ដល់លទ្ធផលនៃការពិភាក្សា និងពិចារណារបស់គណៈកម្មការវិន័យ ឬក្នុងករណីនាយកប្រតិបត្តិយល់ឃើញថា ករណីនោះគួរមានការពិភាក្សា និងពិចារណាបន្ថែម។

33. ការសម្រេចចិត្តក្នុងការដាក់ទណ្ឌកម្ម មិនមានផលប៉ះពាល់ដល់សិទ្ធិណាមួយ ដែលមូលនិធិសកលមានទាក់ទងនឹងអ្នកផ្គត់ផ្គង់ អ្នកស្នងពីអ្នកផ្គត់ផ្គង់ ឬតំណាងអ្នកផ្គត់ផ្គង់ រួមទាំងសិទ្ធិដែលមានចែងក្នុងកិច្ចសន្យាពាក់ព័ន្ធ។

## ការចែករំលែកព័ត៌មានអំពីសេចក្តីសម្រេច

34. ក្នុងករណីនាយកប្រតិបត្តិសម្រេចដាក់ទណ្ឌកម្ម សេចក្តីសម្រេចនោះត្រូវជូនដំណឹងដល់អ្នកផ្គត់ផ្គង់ និងស្ថាប័នទទួលជំនួយទាំងអស់ ក្នុងករណីការប្រព្រឹត្តនោះ អាចប៉ះពាល់ដល់ជំនួយរបស់មូលនិធិសកល ដោយចម្លងជូនប្រធានយន្តការសម្របសម្រួលប្រចាំប្រទេស (Country Coordinating Mechanism) និងភ្នាក់ងារផ្តល់ជំនួយក្នុងតំបន់ (Local Fund Agent)។

35. សេចក្តីជូនដំណឹងដល់អ្នកផ្គត់ផ្គង់ត្រូវបញ្ជាក់អំពី ៖
   (a) ការពិពណ៌នាអំពីការដាក់ទណ្ឌកម្ម
   (b) រយៈពេលនៃការដាក់ទណ្ឌកម្ម និង
   (c) សេចក្តីសង្ខេបអំពីមូលហេតុនៃការសម្រេចចិត្តដាក់ទណ្ឌកម្ម

36. មូលនិធិសកលរក្សាសិទ្ធិក្នុងការកំណត់អំពីវិធី និងទំហំនៃការផ្សព្វផ្សាយសេចក្តីសម្រេចរបស់ខ្លួន រួមមាន ថាតើត្រូវផ្សព្វផ្សាយជាពីសាធារណៈតាមគេហទំព័ររបស់ខ្លួន ឬតាមរយៈវិធីផ្សេងៗ។

37. មូលនិធិសកលអាចចែករំលែកសេចក្តីសម្រេចអំពីការដាក់ទណ្ឌកម្ម ក៏ដូចជាព័ត៌មាន និងភស្តុតាងពាក់ព័ន្ធនឹងសេចក្តីសម្រេច ជាមួយនឹងដៃគូ និងអង្គការអន្តរជាតិ ដោយផ្អែកលើការសន្យារក្សាការសម្ងាត់ដែលតម្រូវដោយអគ្គាអធិការ ឬណែនាំដោយអ្នកប្រឹក្សាផ្នែកច្បាប់។

38. នាយកប្រតិបត្តិត្រូវទទួលខុសត្រូវក្នុងការអនុវត្តន៍សិទ្ធិរបស់មូលនិធិសកល ដូចមានចែងក្នុងកថាខ័ណ្ឌ 33 និង 34 ខាងលើ។ កត្តានានា ដែលត្រូវពិចារណាក្នុងការកំណត់ថាតើ ព័ត៌មានអំពីសេចក្តីសម្រេចនោះគួរត្រូវបានចែករំលែកឬអត់ ក្នុងករណីចែករំលែក ថាតើចែករំលែកឲ្យនរណាខ្លះ កត្តាក្នុងការពិចារណារួមមាន (i) ការធ្វើឲ្យការស៊ើបអង្កេតរបស់ OIG ប្រឈមនឹងគ្រោះថ្នាក់ (ii) សំណូមពររបស់អាជ្ញាធរជាតិក្នុងការដាក់កំហិតលើការផ្សព្វផ្សាយព័ត៌មាន (iii) ការពិចារណាលើផ្នែកច្បាប់ និង (iv) ការការពារអ្នកផ្តល់ព័ត៌មាន និងសាក្សី។

39. បន្ទាប់ពីការពិនិត្យឡើងវិញនូវករណីដែលត្រូវដាក់ជូនគណៈកម្មការវិន័យ ហើយក្នុងករណីគណៈកម្មការវិន័យផ្តល់អនុសាសន៍ថាមិនចាំបាច់ ឬមិនសមស្របក្នុងការដាក់ទណ្ឌកម្មទេ ជាធម្មតា មូលនិធិសកលនឹងជូនដំណឹងដល់អ្នកផ្គត់ផ្គង់អំពីព័ត៌មាននេះ។ ទោះបីជាយ៉ាងណាក៏ដោយ មូលនិធិសកលអាចនឹងមិនជូនដំណឹងដល់អ្នកផ្គត់ផ្គង់ ក្នុងករណីមិនចាំបាច់ណាមួយ ដូចជានៅពេលដែលបញ្ហានោះត្រូវបានផ្សព្វផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយ ឬក្នុងករណី OIG បានជូនដំណឹងដល់អ្នកផ្គត់ផ្គង់រួចហើយនៅក្នុងកំឡុងពេលស៊ើបអង្កេតរបស់ខ្លួន។

## គ្មានការតវ៉ា ឬការពិនិត្យឡើងវិញដោយស្ថាប័នខាងក្រៅ

40. ស្ថាប័នទាំងឡាយមិនមានសិទ្ធិក្នុងការតវ៉ាចំពោះសេចក្តីសម្រេចរបស់មូលនិធិសកលទេ។

41. នីតិវិធីនៃការដាក់ទណ្ឌកម្មនេះ គឺជាដំណើរការធ្វើការសម្រេចចិត្តផ្ទៃក្នុង ហើយសេចក្តីសម្រេចដែលធ្វើឡើងដោយមូលនិធិសកលក្រោមនីតិវិធីនៃការដាក់ទណ្ឌកម្មនេះ មិនតម្រូវឲ្យមានការពិនិត្យឡើងវិញដោយប្រពន្ធ័ច្បាប់ ឬរដ្ឋបាលដោយស្ថាប័ន ឬបុគ្គល ឬភាគីខាងក្រៅឡើយ។

## ការពិនិត្យឡើងវិញផ្ទៃក្នុងបន្ថែម

42. ផ្អែកលើការសម្រេចចិត្ត គណៈកម្មការវិន័យអាចពិនិត្យឡើងវិញនូវអនុសាសន៍មុនៗ ដែលរួមមានសេចក្តីសម្រេចមិនដាក់ទណ្ឌកម្មក្នុងកាលៈទេសៈណាមួយដូចខាងក្រោម ៖
   (a) នៅពេលមានការជូនដំណឹងពីអគ្គាអធិការអំពីព័ត៌មានពាក់ព័ន្ធថ្មី ក្នុងការធ្វើសវនកម្ម ឬការស៊ើបអង្កេតដែលបានធ្វើរទៅពីមុន ឬធ្វើការពិចារណាលើកមុនដោយគណៈកម្មការវិន័យ
   (b) ការធ្វើសេចក្តីសន្និដ្ឋានពីការស៊ើបអង្កេតដោយអាជ្ញាធរជាតិ ឬអង្គការដៃគូ
   (c) របាយការណ៍ចុងក្រោយរបស់ OIG បន្ទាប់ពីបានធ្វើសេចក្តីសន្និដ្ឋានពីការធ្វើសវនកម្ម ឬការស៊ើបអង្កេតរបស់ OIG
   (d) របាយការណ៍បំពេញបន្ថែម ឬចុងក្រោយដោយ OIG និងលេខាធិការដ្ឋាន

(e) ការផ្ញើរព័ត៌មានពាក់ព័ន្ធ ដែលទើបរកឃើញថ្មីៗដោយអ្នកផ្គត់ផ្គង់

**បដិទាន**

43. ក្នុងករណីមូលនិធិសកល បានដាក់ទណ្ឌកម្មសម្រាប់រយៈពេលជាក់លាក់ណាមួយ ការដាក់ទណ្ឌកម្មនោះត្រូវបានលុបចោលដោយស្វ័យប្រវត្តិ បន្ទាប់ពីរយៈពេលនៃការដាក់ទណ្ឌកម្មនោះបានបញ្ចប់។ ក្នុងករណីការដាក់ទណ្ឌកម្មនោះមានរួមបញ្ចូលនូវលក្ខខ័ណ្ឌនានា ការដាក់ទណ្ឌកម្មនោះនឹងត្រូវបានលុបចោលដោយមានការជូនដំណឹងទៅអ្នកផ្គត់ផ្គង់ ពីមូលនិធិសកលដោយបញ្ជាក់ថាគណៈកម្មការវិន័យពេញចិត្ត នៅពេលដែលលក្ខខណ្ឌទាំងនោះបានត្រូវ បំពេញ។

44. ការស្តារឡើងវិញនូវតួនាទីរបស់អ្នកផ្គត់ផ្គង់ដែលធ្លាប់ទទួលការដាក់ទណ្ឌកម្ម ឬការបន្តដាក់ទណ្ឌកម្មបន្ថែមអាចត្រូវបានពិចារណាតែក្នុងមូលហេតុដូចខាងក្រោមប៉ុណ្ណោះ ៖
   (a) ការបង់ថ្លៃបដិទានសម្រាប់ការខូចខាត ឬការបាត់បង់
   (b) ការផ្លាស់ប្តូរថ្នាក់គ្រប់គ្រង ឬភាពជាម្ចាស់ រួមមានការបញ្ឈប់មន្ត្រី និងបុគ្គលិកដែលប្រព្រឹត្តអំពើដែលអាចត្រូវបានដាក់ទណ្ឌកម្ម
   (c) យន្តការសមស្របក្នុងការធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រង ក្រមសីលធម៌ និងការត្រួតពិនិត្យរបស់អាជីវកម្ម
   (d) ការអនុម័តក្បួនច្បាប់ស្តីពីក្រមសីលធម៌ និងក្បួនច្បាប់ប្រឆាំងអំពើពុករលួយ កម្មវិធីបណ្តុះបណ្តាលផ្សេងៗ រួមបញ្ចូលទាំងអ្នកតាមដានឯករាជ្យ
   (e) ការបន្តសហការជាមួយនឹង OIG
   (f) ការចាត់វិធានការរដ្ឋបាល រដ្ឋប្បវេណី ឬព្រហ្មទណ្ឌមានប្រសិទ្ធភាពដោយភាគីដែលត្រូវបានដាក់ទណ្ឌកម្ម នៅពេលដែលត្រូវបានដាក់ទណ្ឌកម្មដោយមូលនិធិសកល ឬ
   (g) ព័ត៌មានណាមួយដែលភាគីដែលត្រូវបានដាក់ទណ្ឌកម្ម បានចូលរួមជាបន្តក្នុងសកម្មភាពដែលអាចត្រូវបានដាក់ទណ្ឌកម្ម បន្ទាប់ពីត្រូវបានដាក់ទណ្ឌកម្មដោយ មូលនិធិសកល

**ការធ្វើវិសោធនកម្មលើនីតិវិធីនៃការដាក់ទណ្ឌកម្ម**

45. នីតិវិធីនៃការដាក់ទណ្ឌកម្មនេះគឺជានីតិវិធីរដ្ឋបាលផ្ទៃក្នុងរបស់មូលនិធិសកល។ នីតិវិធីនេះមិនមែនជាការផ្តល់សិទ្ធិ ឬបុព្វសិទ្ធិអ្វីមួយនោះទេ។

46. មូលនិធិសកលអាចធ្វើវិសោធនកម្មបន្ថែម ឬកែសម្រួលនីតិវិធីនៃការដាក់ទណ្ឌកម្មនេះនៅពេលណាមួយ ដោយមាន ឬមិនមានការជូនដំណឹង។

47. គ្មានផ្នែកណាមួយក្នុងនីតិវិធីនៃការដាក់ទណ្ឌកម្មនេះ ឬក្នុងការអនុវត្តន៍នៃនីតិវិធីនៃការដាក់ទណ្ឌកម្មនេះត្រូវបានពិចារណាកែប្រែ លុបចោល ឬបោះបង់ចោលនូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់មូលនិធិសកលនោះទេ។